# សេចក្តីប្រកាសស្តីពី អ្នកការពារសិទ្ធិមនុស្ស

*សេចក្តីប្រកាសស្តីសិទ្ធិ និងទំនួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការនៅក្នុងសង្គម ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល*

០៩ ធ្នូ ១៩៩៨

ថ្ងៃដែល សេចក្តីប្រកាស ត្រូវបានអនុម័ត

ត្រូវបានអនុម័តជាឯកច្ឆន្ទដោយ **មហាសន្និបាតអង្គការសហប្រជាជាតិ**

## តើនរណាជា **អ្នកការពារសិទ្ធិមនុស្ស?**

បុរស និងស្ត្រី ដែលធ្វើសកម្មភាព ដើម្បីឲ្យមានការគោរពសិទ្ធិមនុស្ស ដូចជា សិទ្ធិសេរីភាពនៃការបញ្ចេញមតិ សិទ្ធិស្ត្រី សិទ្ធិជនជាតិដើមភាគតិច ឬបុរសស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រីស្រឡាញ់ភេទដូចគ្នា សិទ្ធិអ្នកកែភេទ និង បុគ្គលដែលមានអត្តសញ្ញាណភេទពីរ។ ពួកគេអាចធ្វើសកម្មភាពតែម្នាក់ឯង ឬធ្វើការងារនៅក្នុងអង្គការ។

## តើអ្នកអាចគាំទ្រ **អ្នកការពារសិទ្ធិមនុស្ស** បានយ៉ាងដូចម្តេច?

- ផ្សព្វផ្សាយព័ត៌មានអំពីសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស
- រួមចំណែកដល់ការទទួលស្គាល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស
- ជួយគាំទ្រអង្គការដែលជួយ និងការពារ អ្នកការពារសិទ្ធិមនុស្ស
- ធ្វើសកម្មភាពជំនួសអ្នកការពារសិទ្ធិ នៅពេលដែលអ្នកការពារទាំងនោះប្រឈមនឹងហានិភ័យ
- ធ្វើជាអ្នកការពារសិទ្ធិមនុស្ស! គ្រប់គ្នាមានសិទ្ធិ និងទំនួលខុសត្រូវ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស

## តើលក្ខណៈនៃសេចក្តីប្រកាសយ៉ាងដូចម្តេច?

សេចក្តីប្រកាសនេះ ធ្វើឡើងដោយផ្អែកលើ ដោយរួមបញ្ចូលគ្នា និងឆ្លុះបញ្ចាំងទៅលើច្បាប់អន្តរជាតិដែលមានចំណងកាតព្វកិច្ចផ្លូវច្បាប់ ពាក់ព័ន្ធនឹងការលើកស្ទួយ គាំពារ និងការពារសិទ្ធិមនុស្ស។

## សិទ្ធិ និង ការការពារ ដែលត្រូវបានផ្តល់ឱ្យ ទៅ អ្នកការពារសិទ្ធិមនុស្ស

- ដើម្បីលើកស្ទួយសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ពួកគេ និងនៅទូទាំងពិភពលោក
- ការពារសិទ្ធិមនុស្សតែម្នាក់ឯង ឬសហការគ្នាជាមួយអ្នកដទៃ
- ដើម្បីបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ដើម្បីជួបជុំ ឬប្រមូលផ្តុំគ្នាដោយសន្តិវិធី
- ដើម្បីស្វែងរក មាន ទទួលបាន និងគ្រប់គ្រងព័ត៌មាន ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស
- ដើម្បីបង្កើត និងពិភាក្សាពីគំនិត និងគោលការណ៍ថ្មីៗ ស្តីពីសិទ្ធិមនុស្ស និងដើម្បីតស៊ូមតិឱ្យមានការទទួលយកគំនិត និងគោលការណ៍ទាំងនោះ
- ដាក់សំណើ និងមតិរិះគន់ ទៅអាជ្ញាធរនានា ដើម្បីធ្វើឱ្យការធ្វើការងាររបស់ពួកគេ កាន់ប្រសើរឡើង និងជូនដំណឹងដល់ពួកគេ
- ដើម្បីដាក់ពាក្យបណ្តឹងអំពីគោលការណ៍ផ្លូវការ និងសកម្មភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងដើម្បីឱ្យមានការពិនិត្យលើពាក្យបណ្តឹងទាំងនោះ
- ដើម្បីផ្តល់ឱ្យនូវជំនួយផ្លូវច្បាប់ដែលមានវិជ្ជាជីវៈ និងគុណភាព ឬការប្រឹក្សាយោបល់ និងជំនួយផ្សេងទៀតក្នុងការការពារសិទ្ធិមនុស្ស
- ដើម្បីចូលរួមក្នុងសវនាការសាធារណៈ និងនីតិវិធីតុលាការនានា ដើម្បីវាយតម្លៃទៅលើការប្រតិបត្តិរបស់អាជ្ញាធរទៅលើការអនុវត្តច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិនានា
- ដើម្បីទាក់ទងគ្នាដោយគ្មានការរឹតត្បិតណាមួយ ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាលនានា
- ដើម្បីទទួលបានប្រយោជន៍ពីដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយ
- ដើម្បីអាចធ្វើការងារ ឬប្រកបវិជ្ជាជីវៈ ជាអ្នកការពារសិទ្ធិមនុស្សដោយស្របច្បាប់
- ដើម្បីទទួលបានការការពារដ៏មានប្រសិទ្ធភាព តាមច្បាប់ជាតិ នៅពេលធ្វើសកម្មភាពអហិង្សា ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស
- ដើម្បីអង្គាស ទទួល និងប្រើប្រាស់ធនធាន ក្នុងគោលបំណងការពារសិទ្ធិមនុស្ស

មាត្រា ១, ៥, ៦, ៧, ៨, ៩, ១១, ១២ និង១៣

## កាតព្វកិច្ច របស់ រដ្ឋ

- ដើម្បីការពារ លើកស្ទួយ និងអនុវត្តសិទ្ធិមនុស្សទាំងអស់
- ដើម្បីធានាថា មនុស្សគ្រប់រូបដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនទទួលបាននូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានទាំងអស់
- ដើម្បីអនុម័តវិធានការច្បាប់ រដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឱ្យមានប្រសិទ្ធិភាពនៃការអនុវត្តសិទ្ធិ និងសេរីភាព
- ដើម្បីផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធិភាពមួយសម្រាប់មនុស្ស ដែលអះអាងថា ជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស
- ដើម្បីធ្វើការសើបអង្កេតឱ្យបានឆាប់រហ័ស និងដោយឥតលំអៀង ទៅលើការរំលោភសិទ្ធិមនុស្សដែលត្រូវបានគេចោទប្រកាន់
- ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាការការពារមនុស្សគ្រប់រូប ប្រឆាំងនឹងអំពើហិង្សា ការគំរាមកំហែង ការសងសឹក ការរើសអើងអវិជ្ជមាន ការដាក់សម្ពាធ ឬសកម្មភាពតាមទំនើងចិត្តផ្សេងៗ ដែលជាផលវិបាកចេញពីការងារសិទ្ធិមនុស្សរបស់ពួកគេ
- ដើម្បីលើកស្ទួយការយល់ដឹងរបស់សាធារណជនអំពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ដើម្បីធានា និងគាំទ្រ ការបង្កើតនិងការអភិវឌ្ឍស្ថាប័នសិទ្ធិមនុស្សឯករាជ្យថ្នាក់ជាតិ
- ដើម្បីលើកស្ទួយ និងសម្របសម្រួលការបង្ហាត់បង្រៀនអំពីសិទ្ធិមនុស្សនៅគ្រប់កម្រិតនៃវិស័យអប់រំក្នុងប្រព័ន្ធ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ

មាត្រា ២, ៩, ១២, ១៤ និង១៥

## ទំនួលខុសត្រូវ របស់ មនុស្សគ្រប់រូប

- ដើម្បីលើកស្ទួយសិទ្ធិមនុស្ស ដើម្បីការពារលទ្ធិប្រជាធិបតេយ្យ និងស្ថាប័ននៃលទ្ធិប្រជាធិបតេយ្យនានា និងដើម្បីមិនរំលោភបំពានសិទ្ធិមនុស្សរបស់អ្នកដទៃ
- បុគ្គលម្នាក់ៗ អនុវត្តការងារវិជ្ជាជីវៈ ដែលអាចប៉ះពាល់ដល់សិទ្ធិមនុស្សរបស់អ្នកដទៃ។ ជាពិសេសមន្ត្រីនគរបាល មេធាវី ចៅក្រម -ល- ត្រូវមានទំនួលខុសត្រូវក្នុងការការពារសិទ្ធិទាំងនេះ

មាត្រា ១០, ១១និង ១៨

*សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖* www.protecting-defenders.org

Design by Oh ! Ilaliss